- បានឃើញ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ០០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក តាមប្រការ កថាខណ្ឌ វាក្យខណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .

**សំរេច**

**មាត្រា ១ .-** ដោយអនុលោមទៅតាមមាត្រា ៥៦ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ត្រូវបានអនុញ្ញាតឱ្យបើកបន្ថែមឥណទានថវិកាចំនួន ១.៥៣០ លានរៀល (មួយពាន់ប្រាំរយសាមសិបលានរៀល) ទៅលើគម្រោងថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

**មាត្រា ២ .-** ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើត្រូវបានចុះបន្ថែមទៅជំពូក ១៣ (សោហ៊ុយភាពនៃកម្មវិធី) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ ដើម្បីបំពេញតំរូវការចំណាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។

**មាត្រា ៣ .-** ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូកតាមប្រការ កថាខណ្ឌ និងវាក្យខណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៤ .-** ឥណទានថវិកាបន្ថែមនេះ ត្រូវរដ្ឋសភាពិនិត្យអនុម័តជាបន្ទាន់ក្នុងច្បាប់ហិរញ្ញវត្ថុបន្ថែមមួយ ការបើកចំណាយពីគោលនេះ ត្រូវបានចប់សព្វគ្រប់ ។

**មាត្រា ៥ .-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

**អ៊ឹង ហួត** **ហ៊ុន សែន**

★★★

**អនុក្រឹត្យ ៧២ អនក្រ.បក**

**ស្តីពីការបង្កើតក្រុមហ៊ុន ហ្វ្រីនត្រេដ**

*****

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពី ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ ព្រះរាជក្រមលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៨

**សំរេច**

## ជំពូក១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-** ត្រូវបានបង្កើតសហគ្រាសសាធារណៈ ដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះក្រុមហ៊ុន គ្រីន ត្រេដ សរសេរកាត់ គ ហ ត ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងពាណិជ្ជកម្ម និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- គ ហ ត មានទីស្នាក់ការនៅអាគារលេខ ២៤ ផ្លូវប៉ាស្ទ័រ សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ ក្រុងភ្នំពេញ
- គ ហ ត គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ

ក ស ត ត្រូវស្ថិតក្រោមឥទ្ធិពលបទបញ្ញត្តិ នៃអនុក្រឹត្យនេះហើយនឹងគោរពតាមបទបញ្ញត្តិ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈព្រមទាំងបទបញ្ញត្តិ នៃច្បាប់ពាណិជ្ជកម្ម ។

មាត្រា ២ .- ក ស ត មានភារកិច្ចធ្វើពាណិជ្ជកម្ម ផលិតកម្ម និងសេវាកម្មទៅលើមុខទំនិញស្បៀង និងម្ហូប អាហារជាម្ហូបមូលដ្ឋានដោយផ្ទាល់នៅក្នុងក្របខ័ណ្ឌក្នុង និងក្រៅប្រទេស ។ ក្រៅពីមុខទំនិញស្បៀង និងម្ហូបអាហារ ក ស ត ត្រូវធ្វើអាជីវកម្ម ពាណិជ្ជកម្ម ផលិតកម្ម និងសេវាកម្ម ព្រមទាំងនាំចេញ-នាំចូល លើមុខទំនិញផ្សេងទៀត ដូចអាជីវករឯកជនដទៃទៀតដែរ ៖

១- ទិញលក់ផលិតផលស្បៀង និងម្ហូបអាហារ ក្នុងគោលដៅរក្សាស្ថេរភាពទីផ្សារ និងគ្រទ្រង់ថ្លៃស្បៀងរបស់កសិករ ។

២- រួមចំណែកក្នុងការគ្រប់គ្រងការនាំចេញ-នាំចូលស្បៀង និងម្ហូបអាហារ ដោយផ្អែកលើមូលដ្ឋាននៃតុល្យភាពមុខទំនិញ និងម្ហូបអាហារទូទាំងប្រទេស ។

៣- រួមចំណែកគ្រប់គ្រងសន្និធិស្តុកបម្រុងជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

៤- រួមចំណែកផ្គត់ផ្គង់ស្បៀង និងម្ហូបអាហារជាប់ត្រូវតាមសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាល។

៥- ធ្វើរាល់សកម្មភាពអាជីវកម្ម ដូចមានចែងនៅក្នុងលក្ខន្តិកៈ ។

មាត្រា ៣ .- ក ស ត ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១- ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២- អនុក្រឹត្យស្តីពីការបង្កើត ក ស ត

៣- លក្ខន្តិកៈ ក ស ត

៤- ច្បាប់និងបទបញ្ញ[illegible]ក្រុមហ៊ុនពាណិជ្ជកម្ម ចំពោះបទបញ្ញត្តិទាំងឡាយ ដែលមិនផ្ទុយទៅនឹងអត្ថបទខាង[illegible]ី ។

មាត្រា ៤ .- ក ស ត ត្រូវបង់ពន្ធអាករ [illegible]ច្បាប់ និងបទបញ្ញត្តិជាធរមាន ។

មាត្រា ៥ .- ដើមទុនដំបូងនៃ ក ស ត ត្រូវកំណត់ឡើងតាមរយៈការផ្ទេរទុនសរុប នៃបញ្ជីតុល្យការចុងគ្រារបស់ក្រុមហ៊ុនទាំងបីមាន ក្រុមហ៊ុនស្បៀងកម្ពុជា ក្រុមហ៊ុនសម្ភារៈបរិក្ខារ និងក្រុមហ៊ុនប្រមូលទិញកសិផល និងរុក្ខផល ។ ក្រុមហ៊ុនទាំង ៣នេះ ត្រូវរំលាយជាស្វ័យប្រវត្តិនៅពេល ដែល អនុក្រឹត្យនេះចូលជាធរមាន ។

មាត្រា ៦ .- បុគ្គលិករបស់ ក ស ត បានមកពីមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនទាំងបី ក្នុងដំណាក់កាលផ្ទេរតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

- បុគ្គលិករបស់ ក ហ ត ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក២

## ការដឹកនាំ និង គ្រប់គ្រង

មាត្រា ៧ .- ក ហ ត ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងទូលំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌបទបញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈបុគ្គលិករបស់ខ្លួន ។

- ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + តំណាងក្រសួងពាណិជ្ជកម្ម | ០១រូប | ជាប្រធាន |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ០១រូប | ជាសមាជិក |
| + តំណាងក្រសួងផែនការ | ០១រូប | ជាសមាជិក |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | ជាសមាជិក |
| +តំណាងនិយោជិក ក ហ ត | ០១រូប ជាសមាជិកស្ម័គ្រចិត្ត | |
| + អគ្គនាយក ក ហ ត | ០១រូប | ជាសមាជិក |

មាត្រា ៨ .- សមាជិកក្រុមប្រឹក្សាភិបាល ជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥(ប្រាំ) ឆ្នាំ ឬជាឥស្សរៈជនដែលមានអាយុមិនលើសពី ៦៥ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មព្រហ្មទណ្ឌក្រិតធ្ងន់ពីតុលាការឡើយ ។

- សមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ០៣ឆ្នាំ ។ អាណត្តិនេះ អាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិក ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត ក ហ ត ។

មាត្រា ៩ .- ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាមនៃ ក ហ ត ក្នុងការរៀបចំលិខិតស្នាមរាល់ឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី ៖

១- ផ្តល់ការយល់ព្រមលើគំរោងសហគ្រាសដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវគម្រោងផលដែលបានគ្រោងទុកព្រមទាំងចាត់វិធានការ ដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការ គណនីប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពរបស់ ក ម ត ។

៤- សំរេចតាមសំណើរបស់អគ្គនាយកនូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈបុគ្គលិករបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈ និងកំរិតប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់និយោជិត ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា ដែលជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ញាជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេចបង្កើត បើក ឬបិទការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ ក ម ត តាមការវិនិច្ឆ័យរបស់ខ្លួន ។

មាត្រា ១០.- ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេលវេលាត្រូវការដោយផលប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមាន០៤នាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។ ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ដង ក្នុងរយៈពេល ០៣ខែ ។

- ករណីប្រធានអវត្តមាន ត្រូវជ្រើសរើសសមាជិកណាម្នាក់ ដែលមានវ័យចំណាស់ជាងគេ ដើម្បី ដឹកនាំការប្រជុំ ។
- ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។
- របៀបវារៈនៃការប្រជុំ
ព្រមទាំងឯកសារពាក់ព័ន្ធទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាល គ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
អាចប្រព្រឹត្តទៅបានលុះណាតែ មានវត្តមានសមាជិកយ៉ាងតិច ០៤នាក់ រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជា ពុំគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃ ក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំបាច់ទាមទារកូរ៉ុមទេ ។
- សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការបែកសំលេងមានចំនួនស្មើគ្នា សំលេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១១.- សេចក្តីសំរេច នៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រី

ត្រួតពិនិត្យ រដ្ឋក្រុមហ៊ុនស្ថាប័នដទៃទៀត ដែលមានចែងក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃប្រជុំ ។

- កំណត់ហេតុនេះ ត្រូវមានចុះហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

មាត្រា ១២.- អគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ក ហ ត និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម ។ លើកលែងតែភារកិច្ចដែលមានចែងក្នុងមាត្រា ៩ ។

មាត្រា ១៣.- ក្រុមប្រឹក្សាភិបាល ត្រូវប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះ អគ្គនាយកត្រូវ ៖

១- រៀបចំឯកសារទាំងឡាយដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមដំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ ក ហ ត ។

២- ទទួលដឹកនាំ ក ហ ត លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម និងហិរញ្ញវត្ថុ ។

៣- កំណត់ថ្លៃទិញ-លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្មរបស់ ក ហ ត ។

៤- តំណាងឲ្យ ក ហ ត ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល រដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥- មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងមានសិទ្ធិបញ្ជាត្រួតពិនិត្យបណ្តាភ្នាក់ងារ និងនិយោជិតទាំងអស់របស់ ក ហ ត ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៦- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទ ស្របតាមលក្ខខ័ណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៧- តំណាងឲ្យ ក ហ ត ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់ តវ៉ាការពារក្តីឲ្យ ក ហ ត និងការប្តឹងជំទាស់ផ្សេងៗ ។

៨- មានភារកិច្ចផ្សេងៗទៀត ដែលប្រគល់ឲ្យដោយក្រុមប្រឹក្សាភិបាល ។

មាត្រា ១៤.- លាភការរបស់ក្រុមប្រឹក្សាភិបាល និង ប្រាក់បំណាច់ព្រមទាំងលាភការរបស់អគ្គនាយកត្រូវ កំណត់ដោយក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៥.- ការចុះ និងការអនុវត្តកិច្ចសន្យាដោយ ក ហ ត ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៦.-** ក ម ត ត្រូវកាន់កាប់គណនេយ្យរបស់ខ្លួន ឲ្យបានត្រឹមត្រូវតាមបទបញ្ញត្តិគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ការិយបរិច្ឆេទគណនេយ្យចាប់ផ្ដើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំដដែល ។
- ឈរលើរបាយការណ៍នៃគណនេយ្យជំនាញម្នាក់ ដែលមានមុខងារជាស្នងការ គណនី អគ្គនាយក ក ម ត ត្រូវបញ្ជូនតុល្យការ និងគណនីគ្រប់គ្រងរបស់ក្រុមហ៊ុនឲ្យបានមុនថ្ងៃទី ៣០ ខែមីនា ឆ្នាំបន្ទាប់ នៃឆ្នាំកិច្ចការិយបរិច្ឆេទទៅក្រុមប្រឹក្សាភិបាល ដើម្បីផ្ដល់ការយល់ព្រម ។
- តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់សុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកំឡុងពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យនិងយល់ព្រមលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្ដីពីលក្ខន្តិកៈ នៃសហគ្រាសសាធារណៈ ។

**មាត្រា ១៧.-** ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិបីការិយបរិច្ឆេទ ។

- លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ដែលបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវចំណាយក្នុងជំពូកបន្ទុកអាជីវកម្មរបស់ ក ម ត ។
- ស្នងការគណនីត្រូវធ្វើរបាយការណ៍ ដើម្បីបញ្ជាក់លើគណនីប្រចាំឆ្នាំ នៃការិយបរិច្ឆេទ មានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដ នៃស្ថានភាពហិរញ្ញវត្ថុរបស់ ក ម ត ។
- បេសកកម្មរបស់ស្នងការគណនីអនុលោមតាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ៤២អនក្រ.បក ចុះ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីស្នងការគណនី នៃសហគ្រាសសាធារណៈ ។
- ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨.-** រៀងរាល់ឆ្នាំមុនថ្ងៃទី ០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្ដល់ការយល់ព្រមលើគំរោងសហគ្រាសប្រចាំឆ្នាំបន្ទាប់របស់ក្រុមហ៊ុនតាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះ ដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណេញប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានចាំបាច់សំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃសហគ្រាស ។

៣- ការប៉ាន់ស្មានថ្លៃទិញ-លក់មុខទំនិញ ដែលស្ថិតក្នុងអាជីវកម្មរបស់ ក ហ ត ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ របស់ ក ហ ត ។

មាត្រា ១៩.- ធនធាននៃ ក ហ ត ជាអាទិ៍មាន ៖

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។
+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យបន្ថែម ។
+ ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ក ហ ត ។
+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ក ហ ត ។
+ ប្រាក់ខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

មាត្រា ២០.- ចំណាយនៃ ក ហ ត រួមមាន ៖

+ ចំណាយប្រក្រតីសំរាប់ដំណើរការ
+ ចំណាយវិនិយោគ
+ ចំណាយសាងសង់ និង ជួសជុល
+ សងបំណុល
+ ចំណាយផ្សេងៗ

មាត្រា ២១.- ក ហ ត អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់ តំរូវការរបស់ខ្លួន ។

មាត្រា ២២.- ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រាក់ចំណេញដែល ក ហ ត ទទួលបានក្រោយពីការទូទាត់ ត្រូវតាមវិធានគណនេយ្យ ក ហ ត មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះ ឲ្យសមស្រប ទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៣.- រដ្ឋធានាចំពោះតែបំណុលណា ដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូក៤
## ទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៤.- រយៈពេល ១៥ថ្ងៃ យ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ក ហ ត ត្រូវផ្ញើជូន ៖

- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ :

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- តំរោងសហគ្រាស (ដូចមានចែងក្នុងមាត្រា ១៧)
- របាយការណ៍ស្តីពីសកម្មភាព-ចំណូលចំណាយ និងគណនីគ្រប់គ្រងទាំងឡាយរបស់ គមត
- របាយការណ៍របស់ស្នងការគណនី ។

**មាត្រា ២៥.-** ត្រូវបានដាក់ឲ្យនៅអម គ ម ត នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួម គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំលេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទបញ្ញត្តិ នៃមាត្រាទី ២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

**មាត្រា ២៦.-** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៧.-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកក្រុមហ៊ុន គ្រីន ត្រេដ ត្រូវអនុវត្តនូវអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★★★

## អនុក្រឹត្យ ២២៨ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

★★★★★

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា